LOWELL PUBLIC SCHOOLS
Henry J. Mroz ការិយាល័យរដ្ឋបាលកណ្តាល
155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 15 ខែកញ្ញាឆ្នាំ 2020

ជូនចំពោះសហគមន៍ Lowell Public Schools ជាទីគោរពរាប់អាន

យើងទន្ទឹងរង់ចាំស្វាគមន៍សិស្សានុសិស្សរបស់យើងត្រឡប់មកវិញនៅថ្ងៃព្រហស្បតិ៍ទី 17 ខែកញ្ញាសម្រាប់ការចាប់ផ្តើមឆ្នាំសិក្សា 2020-21 នេះ។ ដោយសារការពន្យារពេលនៅក្នុងសង្វាក់ផ្គត់ផ្គង់ជាតិ យើងបានទទួលព័ត៌មានពីឈ្មួញរបស់យើងថា ទំនិញដែលនៅសេសសល់នៃសារពើពន្ធដែលបានបញ្ជាទិញជាមុននៃឧបករណ៍បន្សុទ្ធខ្យល់របស់យើង នឹងមិនមកដល់ទាន់ពេលវេលាតាមកាលកំណត់សម្រាប់ថ្ងៃចូលរៀនដំបូងឡើយ។ បច្ចុប្បន្ននេះ យើងមានឧបករណ៍បន្សុទ្ធខ្យល់ 128 គ្រឿងសម្រាប់ប្រើប្រាស់នៅក្នុងមណ្ឌលទាំងមូល។ ដើម្បីធានាបាននូវសុវត្ថិភាពសិស្ស ក្រុមគ្រួសារ និងបុគ្គលិករបស់យើង **យើងបានធ្វើការសម្រេចចិត្តជាដំបូងដើម្បីផ្លាស់ប្តូរផែនការបើកសាលារៀនឡើងវិញរបស់យើងដើម្បីដាក់កម្រិតលើចំនួនថ្នាក់រៀនដោយផ្ទាល់សម្រាប់ការចាប់ផ្តើមឆ្នាំសិក្សានេះ។** ផែនការដែលបានកែប្រែសម្រាប់ការចាប់ផ្តើមសាលារៀនគឺមានដូចខាងក្រោម៖

- សិស្សដែលបានទទួលកៅអីសិក្សាដោយផ្ទាល់នៅសាលារៀនពេលថ្ងៃរបស់យើង - Dr. Janice Adie, Laura Lee Therapeutic and LeBlanc Therapeutic - នឹងនៅតែរាយការណ៍ទៅកាន់អគារសាលារៀនទាំងនេះសម្រាប់ការបង្រៀនដោយផ្ទាល់ ដូចបានកំណត់នៅថ្ងៃព្រហស្បតិ៍ទី 17 ខែកញ្ញាសម្រាប់ថ្ងៃចូលរៀនដំបូង។
- សិស្សដែលបានទទួលកៅអីសិក្សាដោយផ្ទាល់នៅក្នុងកម្មវិធីអប់រំពិសេសដាច់ដោយឡែកខាងក្រោម - បន្ទប់សិក្សាសម្រាប់សិស្សដែលមានជំងឺអូទីសឹម (CSA) ការអប់រំ និងការធ្វើផែនការបំណិនជីវិត (LEAP) និងបន្ទប់សិក្សាផ្អែកលើភាសា - នឹងនៅតែរាយការណ៍ទៅអគារសាលារៀនរបស់ខ្លួនសម្រាប់ការបង្រៀនដោយផ្ទាល់ ដូចបានកំណត់នៅថ្ងៃព្រហស្បតិ៍ទី 17 ខែកញ្ញាសម្រាប់ថ្ងៃចូលរៀនដំបូង។
- សិស្សនៅក្នុងថ្នាក់ទី 1-12 (ដែលមិនត្រូវបានកំណត់ទៅកាន់កម្មវិធីអប់រំពិសេសដាច់ដោយឡែក) ដែលត្រូវបានកំណត់ពេលសម្រាប់ការសិក្សាដោយផ្ទាល់ នឹងចាប់ផ្តើមឆ្នាំសិក្សានៅក្នុងបរិបទសិក្សាពីចម្ងាយ។ **គ្រួសារនឹងទទួលបានព័ត៌មានថ្មីៗអំពីកាលបរិច្ឆេទសម្រាប់ការបន្តកម្មវិធីសិក្សាដោយផ្ទាល់របស់យើងសម្រាប់សិស្សទាំងនេះ។**
- សិស្សសាលាបង្រៀនកូនក្មេង និងសិស្សថ្នាក់មត្តេយ្យដែលបានទទួលកៅអីសិក្សាដោយផ្ទាល់ នឹងនៅតែរាយការណ៍ទៅអគារសាលារៀនរបស់ខ្លួន ដូចបានកំណត់នៅថ្ងៃទី 21 ខែកញ្ញាសម្រាប់ថ្ងៃចូលរៀនដំបូង។
- សិស្សទាំងអស់ដែលបានចុះឈ្មោះក្នុងការសិក្សាពីចម្ងាយនាពេលបច្ចុប្បន្ន នឹងបន្តដូចបានគ្រោងទុក។

ខ្ញុំដឹងថាការណ៍នេះអាចជាការរំខាន និងជាការខកចិត្តប៉ុណ្ណាសម្រាប់ក្រុមគ្រួសារ។ មុនពេលធ្វើការសម្រេចចិត្តនេះ យើងបានប្រើអស់គ្រប់ជម្រើស - ក្នុងតំបន់ និងក្នុងប្រទេស - ដើម្បីធានាបាននូវឧបករណ៍បន្សុទ្ធខ្យល់ដែលយើងត្រូវការជាផ្នែកមួយនៃពិធីការរបស់យើងសម្រាប់ គោលការណ៍ណែនាំសុខភាព និងសុវត្ថិភាពខ្ពស់ដែលចាំបាច់ដើម្បីបើកបន្ទប់រៀនឡើងវិញ។ ទីបំផុត យើងបានធ្វើការប្តេជ្ញាជូនអ្នកដើម្បី ដាក់សុវត្ថិភាពសិស្ស និងបុគ្គលិកជាអាទិភាពកំពូលរបស់យើង ហើយយើងកំពុងប្រកាន់ខ្ជាប់យ៉ាងមុតមាំជាមួយការប្តេជ្ញាចិត្តនេះ។

ក្នុងការរៀបចំផែនការសម្រាប់ឆ្នាំសិក្សាថ្មី យើងបានរៀបចំសម្រាប់សេណារីយ៉ូដូចករណីនេះ ហើយយើងត្រៀមខ្លួនរួចរាល់ដើម្បីប្តូរទៅការសិក្សាពីចម្ងាយទូទាំងមណ្ឌលជាបណ្តោះអាសន្នសម្រាប់សិស្សដែលបានរៀបរាប់ខាងលើ និងបន្តផែនការសិក្សាដោយផ្ទាល់របស់យើងបន្ទាប់ពីត្រួតពិនិត្យចំណុចទិន្នន័យពាក់ព័ន្ធនឹងជំងឺ COVID និងធានាបានទាំងស្រុងនូវបរិក្ខារសុវត្ថិភាព និងអនាម័យ។

ក្នុងការរៀបចំសម្រាប់ថ្ងៃព្រហស្បតិ៍ អ្នកអាចរំពឹងថានឹងស្តាប់ឮដោយផ្ទាល់ពីសាលារៀនរបស់អ្នកអំពីផែនការបុគ្គលរបស់ខ្លួនសម្រាប់វគ្គមានពីចម្ងាយថ្ងៃដំបូងរបស់កូនអ្នក។ អ្នកក៏អាចរំពឹងទុកព័ត៌មានថ្មីៗអំពីសេវាកម្មម្ហូបអាហារ និងការចែកចាយឧបករណ៍សិក្សាតាមអនឡាញផងដែរ។

សូមអរគុណសម្រាប់ភាពបត់បែន និងការយោគយល់អធ្យាស្រ័យរបស់អ្នក នៅពេលដែលយើងព្យាយាមចាប់ផ្តើមឆ្នាំសិក្សាតាមវិធីដែលមានសុវត្ថិភាពបំផុតសម្រាប់សិស្ស និងបុគ្គលិកទាំងអស់របស់យើង។

ដោយក្តីស្មោះស្ម័គ្រ



Dr. Joel D. Boyd

នាយកសាលាប្រចាំមណ្ឌល